ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំឆមាស ឆ្នាំ២០១៨

នៅក្នុងឆមាស ឆ្នាំ២០១៨នេះ ព្រឹទ្ធសភាបានបំពេញការកិច្ចដូចតទៅ:

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖**

-ទទួលការកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០៣លើក

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន១២លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ចំនួន០៧លើក

-អញ្ជើញទទួលសារតាំងពីអគ្គរដ្ឋទូតតែងតាំងថ្មីចំនួន០២លើក

-អនុញ្ញាតឱ្យគណៈប្រតិភូជាន់ខ្ពស់អន្តរជាតិ អង្គទូត និងអង្គការក្រៅរដ្ឋាភិបាលនានាចូលជួបសម្តែងការគួរសម និងសវនាការចំនួន២៥លើក

-អញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗចំនួន៤៩លើក

-អញ្ជើញចុះមូលដ្ឋានតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញ ចំនួន០៨លើក

-បានចុះហត្ថលេខាលើព្រះរាជក្រមចំនួន០៤ច្បាប់ ព្រះរាជក្រឹត្យចំនួន២០៩ច្បាប់ ទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន២១៣ច្បាប់ ធ្វើសំណើក្នុងនាមប្រមុខរដ្ឋស្តីទីចំនួន០៣សំណើ ទទួលសំណើពីរាជរដ្ឋាភិបាលចំនួន១៩០សំណើ ពីប្រធានព្រឹទ្ធសភាស្តីទីចំនួន០២សំណើ ពីរដ្ឋសភាចំនួន០៩សំណើ ពីក្រុមប្រឹក្សារដ្ឋធម្មនុញ្ញចំនួន០២សំណើ ពីក្រសួងព្រះបរមរាជវាំងចំនួន០១សំណើ ផ្តល់យោបល់ និងចុះហត្ថលេខាលើលិខិតផ្សេងៗចំនួន១៦២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៧៦ច្បាប់។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា បាន** :

-ទទួលការកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០៣លើក

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៨លើក ប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ចំនួន០៥លើក

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-អនុញ្ញាតឱ្យគណៈប្រតិភូជាន់ខ្ពស់អន្តរជាតិ អគ្គទូត និងអគ្គការក្រៅរដ្ឋាភិបាលនានាចូលជួបសម្ដែងការគួរសម និងសវនាការចំនួន០១លើក

-អញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗចំនួន១១លើក

-អញ្ជើញចុះមូលដ្ឋានតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន០៧លើក

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៦២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៣៧៨ច្បាប់ ។

**១.៣.ឯកឧត្ដម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន១១លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០៧លើក

-អនុញ្ញាតឱ្យគណៈប្រតិភូជាន់ខ្ពស់អន្តរជាតិ អគ្គទូត និងអគ្គការក្រៅរដ្ឋាភិបាលនានាចូលជួបសម្ដែងការគួរសម សវនាការ និងពិភាក្សាការងារចំនួន១០លើក

-អញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងសិក្ខាសាលា សន្និបាត វេទិកាក្នុងប្រទេស និងក្រៅប្រទេស រួមទាំងពិធីផ្សេងៗចំនួន៣៨លើក

-អញ្ជើញចុះសួរសុខទុក្ខ និងដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន២២លើក

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣៦៩ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៥៩ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គព្រឹទ្ធសភា**

-បានប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន១៣លើក ប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០៨លើក និងបានពិនិត្យ និងឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ចំនួន១៤ច្បាប់ ។

**៣.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងឆមាស ឆ្នាំ២០១៨នេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

**៣.១. មុខងារនីតិកម្ម**

-គណៈកម្មការជំនាញព្រឹទ្ធសភាបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការ ព្រឹទ្ធសភាជាមួយតំណាងរាជរដ្ឋាភិបាល តំណាងរដ្ឋសភា ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងច្បាប់ចំនួន១៤ច្បាប់

-គណៈកម្មការនានាព្រឹទ្ធសភា បានប្រជុំពិភាក្សា និងផ្តល់យោបល់លើការរៀបចំបង្កើតក្រុមភូមិភាគ ក្រុមសមាជិក សមាជិកាព្រឹទ្ធសភា និងក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាជាមួយសភាបណ្តាប្រទេសនានា និងក្រុមការងារអន្តរសភា ។

## ៣.២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

-សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មតាមបណ្តាខេត្ត ក្រុងនានា ចំនួន១០លើក ដើម្បីជួបសវនាការការងារជាមួយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងឈ្វេងយល់អំពី ការអនុវត្តច្បាប់អន្តោប្រវេសន៍នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិជ្រៃធំ និងសិក្សាស្រាវជ្រាវប្រមូលព័ត៌មាន, វឌ្ឍនភាពចែករំលែក និងផ្តល់ព័ត៌មានស្តីពី នីតិវិធីនៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ នីតិកាលទី៦, សភាពការណ៍រួម និងសភាពការណ៍ពាក់ព័ន្ធនឹងវិស័យអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍, ការអនុវត្តសិទ្ធិមនុស្ស និងដោះស្រាយពាក្យបណ្តឹងរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ, ស្រាវជ្រាវប្រមូលព័ត៌មានជាមួយថ្នាក់ដឹកនាំ ស្រុក និងអាជ្ញាធរមូលដ្ឋានក្នុងភូមិភាគ២, ការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តបន្ទាយមានជ័យ ខេត្តប៉ៃលិន ខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម និងខេត្តសៀមរាប ។

## ៣.៣.មុខងារតំណាង

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ បានធ្វើវេទិកាសាធារណៈចំនួន០១លើក ស្តីពី ការផ្សព្វផ្សាយសមិទ្ធផលសំខាន់ៗរបស់ព្រឹទ្ធសភា និងភាពជាតំណាងរបស់ក្រុមសមាជិកព្រឹទ្ធសភា នៅស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ។

-បានទទួលពាក្យបណ្តឹងចំនួន៣២ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន២១ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យ-បណ្តឹងពីស្ថាប័នមានសមត្ថកិច្ចចំនួន០៨ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន ២២ករណី ជំរុញការដោះស្រាយពាក្យបណ្តឹងចំនួន០២ករណី ទទួលពាក្យបណ្តឹងជូនជ្រាបចំនួន៨៦ករណី បានឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន១៨ករណី និងតម្កល់ទុកមិនចាត់ការចំនួន០១ករណី

-សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្ដាខេត្ត ក្រុង រាជធានីទូទាំងប្រទេសចំនួន១,៦៨៩លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗ សរុបចំនួន៧៥១លើក ។

**៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

ថ្នាក់ដឹកនាំ សមាជិក សមាជិកាគណៈកម្មការនានារបស់ព្រឹទ្ធសភា បានអញ្ជើញទៅបំពេញបេសកកម្មក្រៅប្រទេសចំនួន១៨លើក ដើម្បីចូលរួមកិច្ចប្រជុំ ទស្សនកិច្ចសិក្សា សន្និបាត សន្និសីទ សិក្ខាសាលា វេទិកា និងពិធីផ្សេងៗ នៅព្រះរាជាណាចក្រជប៉ុន សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋសិង្ហបុរី សាធារណរដ្ឋសាយព្រឹស សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋឥណ្ឌូនេស៊ី សហព័ន្ធរុស្ស៊ី សហរដ្ឋអាមេរិក ប្រទេសកាណាដា ប្រទេសអារ៉ាប់រួម ប្រទេសស្រីលង្កា និងកោះតៃវ៉ាន់ ។/

ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ